ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៦១/០៩ - ស៊ីនទ្រី**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក: **គល់ វិឡុនា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ: **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ស៊ីន ទ្រី (កម្ពុជា) ចំកាត់**

អាសយដ្ឋាន : ផ្ទះលេខ៤៤២ ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៩១២ ៣៥៣ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

១- លោក គឹម ច័ន្ទសេង — អនុប្រធានការិយាល័យរដ្ឋបាល និងធនធានមនុស្ស

២- លោក សោម ហ៊ុន — អនុប្រធានការិយាល័យសំអាតក្រុង

៣- លោក កង បូផា — អ្នកសម្របសម្រួល និងដោះស្រាយ

២- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធសហជីព-សហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ នៃក្រុមហ៊ុន ស៊ីន ទ្រី**

អាសយដ្ឋាន : ផ្ទះលេខ ២៧ សេ ផ្លូវលេខ ៣៧៦ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១២ ២៨២ ៥៣១ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក មុំ សារ៉ន ប្រធានសហព័ន្ធសហជីព TUFIKEL

២- លោក មុំ បូណា មន្ត្រីសហព័ន្ធសហជីព TUFIKEL

៣- លោក មុំ សារ៉ាន មន្ត្រីសហព័ន្ធសហជីព TUFIKEL

៤- លោក ជា ស៊ីថា ប្រធានសហជីព TUFIKEL ប្រចាំក្រុមហ៊ុនស៊ីនទ្រី

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- បងប្អូនជាថ្នាក់ដឹកនាំសហជីពនៅតែទាមទារឱ្យក្រុមហ៊ុន ស៊ីនទ្រី រក្សាការងារជូនលោក ជា ស៊ីថា និង លោក មាត រឿន នៅដដែល ដោយហេតុថា លោកទាំងពីរ ជាថ្នាក់ដឹកនាំសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ។ ដោយឡែកតំណាងក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនមិនអាចរក្សាការងារជូនលោក ជា ស៊ីថា និងលោក មាត រឿន នៅដដែលបានឡើយ ដោយហេតុថា ជាតំរូវការការងារចាំបាច់របស់ក្រុមហ៊ុន ហើយម្យ៉ាងទៀតលោកទាំងពីរខាងលើ មានស្នាដៃល្អក្នុងការបំរើការងារជូនក្រុមហ៊ុន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៣៥៣ ក.ប./អក/វ.ក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

THE ARBITRATION COUNCIL

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៩ (វេលាម៉ោង ០៨:០០ នាទី ព្រឹក) ។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងស្តីពីករណី ជូនដំណឹងធ្វើកូដកម្ម ដើម្បីទាមទារឱ្យក្រុមហ៊ុនរក្សាការងារជូនលោក ជា ស៊ីថា និង លោក មាគ ឿន នៅដដែល។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារចំនួន០១ចំណុច។ ចំណុចមិនសះជាចំនួន០១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន០១ចំណុចនេះ នៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ (វេលាម៉ោង ០៨:០០ នាទី ព្រឹក)។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចមិនសះជាចំនួន០១ចំណុចនេះ ប៉ុន្តែមិនបានទទួលលទ្ធផលសះជាទេ។ ហេតុនេះហើយ នៅក្នុងរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដោយផ្អែកលើ ភស្តុតាង និង ហេតុផលដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ឧត្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតឧទ្ទេសនាម ជូនលោក គីម ច័ន្ទសេង លោក សោម ហ៊ុន និងលោក កង បូផា លេខ ០១៤៨/០៩ ស.ក.ច ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩។

២- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ស៊ីនទ្រី លេខ ១៣០ ក.ក.ប.វ/អក/អចក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥។

៣- លក្ខន្តិកៈក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) លេខ ៣០៥៨ ពណ.ចបព ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៨។

ARBITRATION COUNCIL

៥- ពាក្យសុំចូលបំរើការងារ, វិញ្ញាបនប័ត្រពិនិត្យកាយសម្បទា, វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា, លិខិតព្រមព្រៀងគំកល់ប្រាក់, សំណើរសុំបញ្ចូលជាបុគ្គលិកបើកបររថយន្ត ក្នុងក្រុមហ៊ុនស៊ីនទ្រី, ប័ណ្ណបើកបរ, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសៀវភៅស្នាក់នៅរបស់ឈ្មោះ ជា ស៊ីថា។

៦- ពាក្យសុំចូលបំរើការងារចំនួនពីរច្បាប់, ប័ណ្ណបើកបរ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់លោក មាគ រឿន។

៧- លិខិតស្តីពីសេចក្តីសម្រេចស្តីពីការបញ្ឈប់ការងារបុគ្គលិក លេខ ០១២៣/០៥ ស.ក.ច ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥។

៨- លិខិតស្តីពីសេចក្តីសម្រេចស្តីពីការបញ្ឈប់ការងារបុគ្គលិក លេខ ០១២២/០៥ ស.ក.ច ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥។

៩- លិខិតរបស់ក្រុមហ៊ុន ជំរាបជូន លោកប្រធានសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ស្តីពីការមិនយល់ព្រមអនុវត្តការចាត់ចែងរបស់ក្រុមហ៊ុន លេខ ០១១៥/០៥ ស.ក.ច ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៥។

១០- លិខិតស្តីពីសេចក្តីសម្រេចស្តីពី ការផ្ទេរការងារអ្នកបើកបររថយន្តដឹកសំរាម លេខ ០១០៨/០៥ ស.ក.ច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៥។

១១- លិខិតរបស់ក្រុមហ៊ុន ជំរាបជូន លោកប្រធានសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ស្តីពីសេចក្តីជូនដំណឹងស្តីពីការផ្ទេរការងារលោក ជា ស៊ីថា និង លោក មាគ រឿន មុខងារជាអ្នកបើកបររថយន្តដឹកសំរាម ពីភ្នំពេញ ទៅបំរើការងារនៅសាខា ខេត្តព្រះសីហនុ លេខ ០១០៧/០៥ ស.ក.ច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៥។

១២- លិខិតស្តីពីសេចក្តីសម្រេចស្តីពី ការផ្ទេរការងារអ្នកបើកបររថយន្តដឹកសំរាម លេខ ០១០៨/០៥ ស.ក.ច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៥។

១៣- កំណត់ហេតុប្រជុំរបស់សាលារាជធានីភ្នំពេញ រវាងក្រុមហ៊ុន ស៊ីនទ្រី នឹងសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៥។

១៤- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥។

១៥- លិខិតស្តីពីសេចក្តីសម្រេចស្តីពីការផ្ទេរភារកិច្ចបុគ្គលិក លេខ ០២១១/០៦ ស.ក.ច ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០៦។

១៦- លិខិតស្តីពីសេចក្តីសម្រេចស្តីពីការផ្លាស់ប្តូរមុខងារ និង ការតែងតាំងបុគ្គលិក លេខ ០២៨៨/០៦ ស.ក.ច ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦។

6

THE ARBITRATION COUNCIL

១៧- លិខិតរបស់ក្រុមហ៊ុន ស៊ីនទ្រី សាខាខេត្តព្រះសីហនុ គោរពជូនលោកប្រធានសាខា ស្តីពីសំណើរសុំជ្រើសរើសបុគ្គលិកបន្ថែម០៣នាក់ តួនាទីជាអ្នកបើកបរ មកពីភ្នំពេញ ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៩។

១៨- សេចក្តីថ្លែងការរបស់ សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ។

១៩- សារណាសង្ខេបនៃវិវាទការងាររបស់ក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៩។

២០- កំណត់ហេតុប្រជុំរបស់សាលារាជធានីភ្នំពេញ រវាងក្រុមហ៊ុន ស៊ីនទ្រី នឹងសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

២១- វិញ្ញាបនប័ត្រចុះបញ្ជិកា និងលិខិតបញ្ជាក់ របស់សហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ លេខ ០៦៦/០៨ កប ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៨។

២២- លិខិតរបស់សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ជំរាបជូនលោកនាយកក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- វិញ្ញាបនប័ត្រចុះបញ្ជិកា និងលិខិតបញ្ជាក់ របស់សហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ លេខ ០៦៦/០៨ កប ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៨។

២- លិខិតរបស់ក្រុមហ៊ុន ស៊ីនទ្រី សាខាខេត្តព្រះសីហនុ គោរពជូនលោកប្រធានសាខា ស្តីពីសេចក្តីរាយការណ៍ស្តីពីការការផ្ទេរការងារបុគ្គលិកពីភ្នំពេញ មកបំរើការងារនៅសាខាក្រុមហ៊ុន ខេត្តព្រះសីហនុ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩។

៣- សេចក្តីជូនដំណឹងរបស់ សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ស្តីពីការរៀបចំធ្វើកូដកម្មដោយអហឹង្សា ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩។

៤- លិខិតអញ្ជើញរបស់សាលារាជធានីភ្នំពេញ អញ្ជើញលោក មុំ សារ៉ន ប្រធានសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចូលរួមប្រជុំស្តីពីការរៀបចំធ្វើកូដកម្មដោយអហឹង្សា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩។

៥- លិខិតរបស់ក្រុមហ៊ុន ជំរាបជូន លោកប្រធានសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ស្តីពីសេចក្តីជូនដំណឹងស្តីពីការផ្ទេរការងារលោក ជា ស៊ីថា និង លោក មាគ រឿន មុខងារជាអ្នកបើកបររថយន្តដឹកសំរាម ពីភ្នំពេញ ទៅបំរើការងារនៅសាខា ខេត្តព្រះសីហនុ លេខ ០១០៧/០៩ ស.ក.ច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩។

៦- កំណត់ហេតុប្រជុំរបស់សាលារាជធានីភ្នំពេញ រវាងក្រុមហ៊ុន ស៊ីនទ្រី នឹងសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

៧- កំណត់ហេតុប្រជុំរបស់សាលារាជធានីភ្នំពេញ រវាងក្រុមហ៊ុន ស៊ីនទ្រី នឹងសហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩។

៨- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

៩- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩។

១០- សារណាសង្ខេបនៃវិវាទការងារ របស់សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៩។

១១- ពាក្យសុំចូលបំរើការងារ។

១២- លិខិតស្តីពីសេចក្តីសម្រេចស្តីពីការផ្លាស់ប្តូរមុខងារ និង ការតែងតាំងបុគ្គលិក លេខ ០២៨៨/០៦ ស.ក.ច ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦។

១៣- ពាក្យសុំចូលបំរើការងារ, វិញ្ញាបនប័ត្រពិនិត្យកាយសម្បទា, វិញ្ញាបនប័ត្របញ្ជាក់ការសិក្សា, លិខិតព្រមព្រៀងតំកល់ប្រាក់, សំណើរសុំបញ្ចូលជាបុគ្គលិកបើកបររថយន្តក្នុងក្រុមហ៊ុន ស៊ីនទ្រី, ប័ណ្ណបើកបរ, អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងសៀវភៅស្នាក់នៅ របស់ឈ្មោះ ជា ស៊ីថា។

១៤- ពាក្យសុំចូលបំរើការងារចំនួនពីរច្បាប់, ប័ណ្ណបើកបរ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់លោក មៀក រឿន។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ីនទ្រី លេខ ៣៥៣ ក.ប./អក/ វ.ក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន ស៊ីនទ្រី ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៣១៦ កប/អក/វក/លកអ. ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៣១៥ កប/អក/វក/លកអ. ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩។

**ការរកឃើញរបស់ហេតុ:**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

THE ARBITRATION COUNCIL

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ស៊ីនទ្រី មានទីតាំងផ្ទះលេខ ៤៤២ ដេ មហាវិថីព្រះមុនីវង្ស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជួលកម្មករនិយោជិតសរុបចំនួនប្រហែល ១ ០៥០នាក់។
- ភាគីកម្មករនិយោជិតដែលជាភាគីនៃដើមបណ្តឹងក្នុងរឿងនេះតំណាងដោយសហជីពលើកតម្កើងជីវភាពកម្មករ និយោជិតខ្មែរ ដែលបានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកានៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨។

**ចំណុចវិវាទទី១ ៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាការងារជូនលោក ជា ស៊ីថា និង មាគ រឿននៅដដែល**

- លោក ជា ស៊ីថា និង មាគ រឿន មានតួនាទីជាអ្នកបើកបររថយន្ត។ លោក ជា ស៊ីថា បានចូលធ្វើការនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៥ ឯលោក មៀត រឿន ចូលធ្វើការនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៤ ។
- ក្រុមហ៊ុនបានផ្លាស់ការងារ ជា ស៊ីថា និង មាគ រឿន ឱ្យទៅធ្វើការនៅខេត្តព្រះសីហនុតាមរយៈសេចក្តីសម្រេច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៩ ដែលសេចក្តីសម្រេចនេះចូលជាធរមាន នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩។ ក្រុមហ៊ុនបានជូនដំណឹងនេះទៅ ជា ស៊ីថា និង មាគ រឿន នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩។ លោក ជា ស៊ីថា បានទទួលលិខិតនេះ ហើយបានចុះហត្ថលេខាថា បានទទួល និងឯកភាព។ ប៉ុន្តែ មាគ រឿន មិនបានទទួលលិខិតនោះដោយផ្ទាល់ទេ គឺ លោក ជា ស៊ីថា ជាអ្នកយកឱ្យ។
- នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ សហព័ន្ធសហជីពលើកតម្កើងជីវភាពកម្មករនិយោជិតខ្មែរ បានជូនដំណឹងទៅក្រុមហ៊ុន ដើម្បីធ្វើកូដកម្មអហឹង្សា ដើម្បីទាមទារឱ្យរក្សាងារងាររបស់លោក ជា ស៊ីថា និង មាគ រឿន នៅភ្នំពេញដដែល ហើយបានចម្លងសេចក្តីជូនដំណឹងនេះ ជូនស្ថាប័នពាក់ព័ន្ធ ដែលក្នុងនោះ មានសាលារាជធានីភ្នំពេញផងដែរ។
- នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ មានកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញទាក់ទងនឹងការផ្អាកកូដកម្មនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩ ក្រោមអធិបតីភាពលោក កើត រ៉ែ ហើយសហព័ន្ធសហជីពបានឯកភាពមិនធ្វើកូដកម្ម។
- នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩ ក្រុមហ៊ុនសម្រេចបញ្ឈប់លោក ជា ស៊ីថា និង លោក មាគ រឿន ដោយសារពួកគេមិនព្រមទៅធ្វើការនៅខេត្តព្រះសីហនុ។ ប៉ុន្តែ នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ មានកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពលោក កើត រ៉ែ ហើយភាគីក្រុមហ៊ុន ស៊ីនទ្រី បានឯកភាព ដូចខាងក្រោម៖
  - *"ចំពោះលោក ជា ស៊ីថា និង លោក មាគ រឿន ក្រុមហ៊ុនអត់បញ្ឈប់គាត់ទេ ហើយឱ្យចូលធ្វើការវិញ។*

- ចំពោះលោក ជា ស៊ីថា និង លោក មាត ភឿន មានស្នាដៃល្អទើបក្រុមហ៊ុនសម្រេចឱ្យទៅធ្វើជាបុគ្គលិកគំរូនៅសាខាក្រុមហ៊ុនកំពង់សោមរយៈពេលប្រាំមួយខែ និងតម្លើងប្រាក់ខែឱ្យ។
- សហជីពមិនឯកភាពតាមសំណើនេះទេ ហើយភាគីទាំងពីរឯកភាពបន្តរង់ចាំសេចក្តីសម្រេចពីក្រុមប្រឹក្សាអាជ្ញាកណ្តាល និងយល់ព្រមអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។"

- នៅសវនាការ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាការងារ ជូនលោក ជា ស៊ីថា និង មាត ភឿន នៅដដែលមូលហេតុប៉ះពាល់ ដល់ស្ថានភាពគ្រួសារ។ លោក ជា ស៊ីថា បញ្ជាក់ថា គាត់មានកូន ៣នាក់: ២នាក់ កំពុងសិក្សានៅថ្នាក់ទី ៦ និង ថ្នាក់ទី ៧ និង ម្នាក់ទៀត ទើបតែមានអាយុជាង ១ឆ្នាំ ដូច្នេះ គាត់មិនអាចទៅចោលគ្រួសារគាត់បានទេ ហើយម្យ៉ាងវិញទៀត គាត់ជាប្រធានសហជីពផង។ លោក មាត ភឿន បានអវត្តមាននៅក្នុងសវនាការ ប៉ុន្តែតំណាងសហជីពបានបញ្ជាក់ថា មូលហេតុដែលលោក មាត ភឿន មិនព្រមទៅមកពីបញ្ហាគ្រួសារដែរ ដោយសារគាត់មានកូនពីរនាក់ ប៉ុន្តែមិនទាន់ចូលរៀននៅឡើយទេ។
- នៅក្នុងសវនាការភាគីក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនត្រូវតែផ្លាស់ការងារលោក ជា ស៊ីថា និង លោក មាត ភឿន ទៅធ្វើការនៅខេត្តព្រះសីហនុ ព្រោះមានការស្នើសុំបន្ថែមអ្នកបើកបរពនាក់ពីអនុប្រធានសាខាខេត្តព្រះសីហនុ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩។ ដូច្នេះ ក្រុមហ៊ុនសម្រេចចិត្តផ្លាស់ លោក ជា ស៊ីថា និង លោក មាត ភឿន ឱ្យទៅខេត្តព្រះសីហនុ ព្រោះពួកគាត់ជាកម្មករនិយោជិតល្អ ក្រុមហ៊ុនចង់ឱ្យគាត់ទៅធ្វើជាគំរូកម្មករនៅទីនោះ។ ក្រុមហ៊ុនមានបំណងឱ្យគាត់ទៅធ្វើការនៅក្រុងព្រះសីហនុរយៈពេល៦ខែ។ ពួកគាត់អាចទៅធ្វើការសាកល្បងរយៈពេល២សប្តាហ៍សិន ប្រសិនបើមិនចូលចិត្ត ឬមានបញ្ហាអ្វីនោះ អាចធ្វើការពិភាក្សាគ្នាបាន។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា ក្នុងការទៅធ្វើការនៅខេត្តព្រះសីហនុនេះ ក្រុមហ៊ុនផ្តល់មធ្យោបាយធ្វើដំណើរទៅមក កន្លែងស្នាក់នៅ និង ឧបត្ថមប្រាក់បៀវត្សបន្ថែម។
- លោក ជា ស៊ីថា និងតំណាងកម្មករនិយោជិត ដែលមានវត្តមានក្នុងសវនាការនៅតែបញ្ជាក់ថា គាត់មិនអាចទៅធ្វើការនៅខេត្តព្រះសីហនុបានទេ ហើយនៅតែទាមទារធ្វើការនៅភ្នំពេញដដែល ហើយករណីប្តូរពួកគេ ទៅខេត្តព្រះសីហនុនេះ សហជីពបានចោទថា ជាការរើសអើងសហជីពផងដែរ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា ការផ្លាស់ប្តូរការងារនេះជាសិទ្ធិចាត់ចែងរបស់ក្រុមហ៊ុន គឺគ្មានការរើសអើងសហជីពទេ ព្រោះក្រុមហ៊ុនមិនដឹងថា ពួកគាត់ជាថ្នាក់ដឹកនាំ និងសកម្មជនសហជីពនោះទេ ទើបតែពេលដែលក្រុមហ៊ុនទទួលលិខិតជូនដំណឹងធ្វើកូដកម្មពីសហព័ន្ធសហជីពទើបដឹង។ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា ខ្លួនបានជូនដំណឹងអំពីការបង្កើតសហជីពទៅក្រុមហ៊ុន តាំងពីពេលទទួលបានបញ្ជិកា។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបង្គាប់ឱ្យភាគីកម្មករនិយោជិតដាក់ភស្តុតាងទាក់ទងនឹងចំណុចនេះ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលឯកសារទាក់ទងនឹងចំណុចនេះទេ។

- ផ្អែកតាមសារណាការពារដែលក្រុមហ៊ុនដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ ២០០៩ ក្រុមហ៊ុនយល់ថាវិវាទនេះជាវិវាទបុគ្គល។

**ហេតុផលនៃសេចក្តីសម្រេច:**

**ចំណុចវិវាទ : កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនរក្សាការងារជូនលោក ជា ស៊ីថា និង មាគ វឿន នៅដដែល**

មុននឹងពិចារណាលើចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាល មានយុត្តាធិការលើវិវាទនេះដែរ ឬទេ?

ជាគោលការណ៍ អធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចក្នុងការសំរេចថា តើវិវាទណាមួយជាវិវាទបុគ្គល ឬវិវាទការងាររួម មុនពេលបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ជាធម្មតាក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងគោរពតាមការសម្រេចរបស់អធិការកិច្ចការងារ និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រសិនបើគ្មានហេតុផលជំទាស់ច្បាស់លាស់នោះទេ (សូមមើលសេចក្តីបង្គាប់នៃសំណុំរឿង*លេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤, លេខ ០២/០៤-សណ្ឋាគារ កាំបូឌីយ៉ាណា , លេខ ៤១/០៤-មីកាសា, និង លេខ ០៧/០៥-កូកា កូឡា*)។

នៅក្នុងសំណុំរឿងនេះ ភាគីក្រុមហ៊ុនយល់ឃើញថា វិវាទនេះជាវិវាទបុគ្គល ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណា ដូចខាងក្រោម :

មាត្រា ៣០២ នៃច្បាប់ការងារចែងថា *" វិវាទការងាររួមគឺជាវិវាទដែលកើតឡើងរវាងនិយោជកម្នាក់ ឬច្រើននាក់ នឹងបុគ្គលិករបស់ខ្លួនមួយចំនួន អំពីរឿងល័ក្ខខ័ណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ការត្រូវទទួលស្គាល់អង្គការវិជ្ជាជីវៈ ក្នុងសហគ្រាស បញ្ហានៃការទាក់ទងរវាងនិយោជក និង កម្មករនិយោជិត ហើយការវិវាទនេះ អាចបណ្តាលឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាព សង្គម ។ "*

ផ្អែកលើមាត្រា ៣០២ នៃច្បាប់ស្តីពីការងារ ដើម្បីអាចនិយាយបានថា វិវាទមួយជាវិវាទរួម ត្រូវបំពេញជាចាំបាច់តាមលក្ខខណ្ឌបីយ៉ាងនៃវិវាទការងាររួម ដូចមានចែងក្នុងច្បាប់ការងារមាត្រា ៣០២។ លក្ខខណ្ឌបីយ៉ាងនោះ គឺ ក- ជាវិវាទរវាងកម្មករមួយចំនួន និងនិយោជកម្នាក់ ឬច្រើននាក់, ខ- បញ្ហានៃវិវាទទាក់ទង នឹងលក្ខខណ្ឌការងារ ការប្រើប្រាស់សិទ្ធិដែលប្រគល់ឱ្យអង្គការវិជ្ជាជីវៈ ទទួលស្គាល់អង្គការវិជ្ជាជីវៈ ឬបញ្ហានៃទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិត និង គ- វិវាទនេះអាចបណ្តាលអាចឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម។

THE ARBITRATION COUNCIL

ក្នុងករណីនេះ លក្ខខណ្ឌ-ក ត្រូវបានបំពេញ ពីព្រោះពាក្យបណ្តឹងនេះបានធ្វើឡើង ដោយសហជីព។ លក្ខខណ្ឌ-ខ ក៏ត្រូវបានបំពេញ ព្រោះវិវាទនេះទាក់ទងនឹងលក្ខខណ្ឌការងារ និងទំនាក់ទំនងការងាររវាង កម្មករនិយោជិត និងនិយោជក។ ចំណែកលក្ខខណ្ឌ-គ ក៏ត្រូវបានបំពេញដែរ ព្រោះវិវាទនេះ អាចនឹងធ្វើឱ្យសហគ្រាសប្រព្រឹត្តទៅពុំបានស្រួល ឬធ្វើឱ្យខូចសន្តិភាពសង្គម ដោយសារកម្មករគម្រាមធ្វើកូដកម្ម ប៉ុន្តែកម្មករបានឯកភាពផ្អាកវិញតាមរយៈកិច្ចប្រជុំនៅសាលារាជធានីភ្នំពេញ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩។

ផ្អែកលើការបកស្រាយខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទនេះគឺជាវិវាទការងាររួម។ ដោយអនុលោមទៅតាមជំពូក១២ ផ្នែកទី២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការក្នុងការសម្រេចលើវិវាទការងាររួម។

ម្យ៉ាងវិញទៀត នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសន្មតថា រាល់ការទាមទារទាំងអស់ នៅក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ គឺជាវិវាទការងាររួម។ ដោយសារតែភាគីនិយោជកបានធ្វើការជំទាស់ទៅនឹងការសន្មតនេះ និយោជកមានបន្ទុកផ្តល់ភស្តុតាងបញ្ជាក់អំពីអំណះអំណាងរបស់ខ្លួន។ (សូមមើលសេចក្តីបង្គាប់ នៃសំណុំរឿង*លេខ ៤៥/០៧ - វីល សិន ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៤*)។

ក្នុងសំណុំរឿងនេះ ភាគីនិយោជកពុំបានផ្តល់ភស្តុតាង ឬ ហេតុផល ដើម្បីបដិសេធទៅនឹងការសន្មតរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលផ្អែកលើក្រសួងការងារដែលបានចាត់ទុកថា វិវាទនេះជាវិវាទរួមនោះទេ ក្រុមហ៊ុនគ្រាន់តែលើកឡើងនៅក្នុងសារណាដែលដាក់មកក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ការទាមទាររបស់កម្មករនិយោជិតនៅក្នុងករណីនេះ ជាករណីវិវាទបុគ្គលប៉ុណ្ណោះ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល រកមិនឃើញថា មានភស្តុតាងពីនិយោជកថា ករណីនេះមិនមែនជាវិវាទរួមឡើយ។

យោងតាមអង្គច្បាប់ និង ភស្តុតាង ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្តាលមានយុត្តាធិការលើករណីវិវាទនេះ។ ហេតុនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើអង្គសេចក្តីដូចតទៅ:

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា " *........នឹងទុកជានិយោជកដែលបង្កើតសហគ្រាស តាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ។ សហគ្រាស... .........។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក*"។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារ ខាងលើនេះ មានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន លុះត្រាតែសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ។ (សូមមើលសេចក្តីបង្គាប់នៃសំណុំរឿង*លេខ ១០៨/០៦-ទ្រីនុងប្លាល គូម៉ា ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និងលេខ ០៨/០៩-ក្លូប័ល អាប៉ារែល*)។

បន្ថែមពីនេះ ក្នុងសំណុំរឿងលេខ ១៧/០៣ និង ១៨/០៣-ហូ ហ៊ីង ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា និយោជកមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន

រួមមាន ការផ្ទេរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ហើយនិងការផ្តល់ឱ្យនូវលក្ខខណ្ឌមួយ ចំនួនដូចជា : (១)-មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃ ទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។

យោងតាមមាត្រា២ នៃច្បាប់ស្តីពីការងារ និងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិក្នុងការចាត់ចែង ផ្លាស់ប្តូរទីតាំងរបស់ក្រុមហ៊ុនពីកន្លែងមួយទៅកន្លែងមួយ ឬផ្លាស់ប្តូរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ឱ្យតែការផ្លាស់ប្តូរនោះធ្វើឡើងដោយ គោរពលក្ខខណ្ឌទាំង៤ ដើម្បីឱ្យស្របច្បាប់ និងមានលក្ខណៈសមរម្យ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការផ្លាស់ប្តូរការងារ លោក ជា ស៊ីថា និង លោក មាគ រឿន មានការប៉ះពាល់ចំពោះលក្ខខណ្ឌទី ២ ដែលកំណត់មិនឱ្យផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ ព្រោះពីភ្នំពេញ ទៅខេត្តព្រះសីហនុ មានចំងាយឆ្ងាយជាង ២០០ គម ឯណោះ។ ប៉ុន្តែទោះបីជាមានចំងាយឆ្ងាយក៏ដោយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការផ្លាស់ប្តូរនេះ និយោជកចាត់វិធានការមានលក្ខណៈសមរម្យ ឬទេ ចំពោះការផ្លាស់ប្តូរកន្លែងការងារបណ្តោះអាសន្ន៦ខែនេះ?

កម្មករនិយោជិត បានបញ្ជាក់ពីហេតុផលមិនព្រមទៅធ្វើការនៅខេត្តព្រះសីហនុថា ដោយសារប៉ះពាល់ដល់ស្ថានភាពគ្រួសារ ព្រោះពួកគេមានកូន និងប្រពន្ធនៅភ្នំពេញ និងការផ្លាស់ប្តូរនេះជាការរើសអើងសហជីព។ ចំណែកឯភាគីក្រុមហ៊ុនបញ្ជាក់ថា ក្នុងការផ្លាស់ពួកគេទៅធ្វើការនៅខេត្តព្រះសីហនុនេះ ក្រុមហ៊ុនផ្តល់មធ្យោបាយធ្វើដំណើរទៅមកផ្តល់កន្លែងស្នាក់នៅ និងឧបត្ថម្ភប្រាក់បៀវត្សបន្ថែម ហើយផ្លាស់ប្តូរតែក្នុងរយៈពេល ៦ខែ ដើម្បីទៅធ្វើជាបុគ្គលិកគំរូ ហើយឱ្យពួកគាត់អាចទៅធ្វើការសាកល្បងរយៈពេល២សប្តាហ៍សិន ប្រសិនបើមិនចូលចិត្តអាចធ្វើការពិភាក្សាគ្នាបាន ហើយការផ្លាស់ប្តូរនេះមិនមែនជាការរើសអើងសហជីពទេ ព្រោះក្រុមហ៊ុនមិនបានដឹងថា ពួកគាត់ជាថ្នាក់ដឹកនាំ ឬសកម្មជនសហជីពទេ។

ទាក់ទងនឹងការលើកឡើងខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តសិទ្ធិចាត់ចែងរបស់និយោជកមិនបំពានមាត្រា ២ នៃច្បាប់ស្តីពីការងារ និង ខុសពីសេចក្តីបង្គាប់មុនៗទេ ព្រោះនេះជាការចាត់តាំងបុគ្គលិកល្អឱ្យទៅធ្វើជាបុគ្គលិកគំរូ ហើយក្រុមហ៊ុនបានធានាថា នឹងផ្តល់មធ្យោបាយធ្វើដំណើរដល់ពួកគេ នៅពេលពួកគេចង់ទៅមកភ្នំពេញដើម្បីជួបជុំគ្រួសារប្រពន្ធកូនផងដែរព្រោះ ដើម្បីដោះស្រាយបញ្ហាភាពកក់ក្តៅក្នុងគ្រួសាររបស់កម្មករនិយោជិតទាំងពីរដែលជាកង្វល់របស់ពួកគេ នៅពេលប្តូរទៅខេត្តព្រះសីហនុនេះ។

ចំពោះការរើសអើងសហជីពវិញ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា មានការរើសអើងសហជីពឬទេ?

មាត្រា ១២ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា " *...គ្មាននិយោជកណាម្នាក់អាចយកបញ្ហា ... ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព។ ដើម្បីជាលេសធ្វើសេចក្តីសំរេច*

*អំពី :... ការកំណត់ និងការបែងចែកការងារ...*" ។ យោងតាមមាត្រា ១២ ខាងលើនេះ បានន័យថា ច្បាប់ហាម និយោជករើសអើងសហជីព ក្នុងការកំណត់ និងការបែងចែកការងារកម្មករនិយោជិតទេ ។

ទាក់ទងនឹងការរើសអើងសហជីព ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព។ (សូមមើល សេចក្តីបង្គាប់សំណុំរឿង*លេខ ៩៣/០៦-អេវើហ្គ្រីន ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ លេខ ១១២/០៦-វីវើច ហេតុផលនៃសេចក្តីសម្រេច ចំណុចវិវាទទី១ និង លេខ ០១/០៧-ស៊ុខ គ្រីម ហេតុផល នៃសេចក្តីសម្រេច ចំណុចវិវាទទី១*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយខាងលើដែរ ហើយតាមអង្គហេតុ ភាគីកម្មករនិយោជិតមិនមានភស្តុតាងគ្រប់គ្រាន់ក្នុងការបង្ហាញថា ការផ្លាស់ប្តូរលោក ជា ស៊ីថា និង មាគ រឿន ទៅខេត្តព្រះសីហនុចំនួន៦ខែនេះ ជាការរើសអើងសហជីពទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា គ្មានការរើសអើងសហជីពទេចំពោះការប្តូរការងារលោក ជា ស៊ីថា និង មាគ រឿន ទៅខេត្តព្រះសីហនុចំនួន ៦ ខែនេះទេ។

សរុបសេចក្តីមកក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផ្លាស់ប្តូរលោក ជា ស៊ីថា និងលោក មាគ រឿន ទៅខេត្តព្រះសីហនុ ធ្វើឡើងដោយសមរម្យ និង គ្មានការរើសអើងនឹងសហជីព ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចដូចតទៅ :

## សម្រេច និង បង្គាប់

- បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យលោក ជា ស៊ីថា និង មាគ រឿន ធ្វើការនៅភ្នំពេញដដែល ។
- បង្គាប់ឱ្យនិយោជកផ្លាស់ប្តូរទីកន្លែងការងាររបស់លោកទាំងពីរពីភ្នំពេញទៅខេត្តព្រះសីហនុ តែក្នុងរយៈពេល៦ខែ ចាប់ពីថ្ងៃសេចក្តីបង្គាប់នេះចូលជាធរមាន ដោយផ្តល់មធ្យោបាយធ្វើដំណើរទៅមក ផ្តល់កន្លែងស្នាក់នៅ និងឧបត្ថម្ភប្រាក់បៀវត្សបន្ថែម ដើម្បីឱ្យកម្មករនិយោជិតទាំងពីរទៅធ្វើជាបុគ្គលិកគំរូ និងធ្វើការសាកល្បងរយៈពេល២សប្តាហ៍ ប្រសិនបើមិនចូលចិត្តអាចធ្វើការពិភាក្សាគ្នាបាន។

ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **គល់ បញ្ញា**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន វីរៈ**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: ------------------------------

THE ARBITRATION COUNCIL